# របៀបអធិស្ឋាន៧យ៉ាងដ៏សាមញ្ញប្រចាំថ្ងៃ

ការដែលយើងមិនចំណាយពេលអធិស្ឋាន គឺជាការដែលនាំមិនឲ្យយើងមានភាពអរសប្បាយដ៏ពិត។ បើសិនជាយើងបោះបង់ចោលការអធិស្ឋាន ឬបដិសេធមិនចង់អធិស្ឋាន នោះមានន័យថា យើងព្រមបោះបង់ចោលនូវប្រភពដ៏ល្អបំផុតនៃសេចក្តីអំណររបស់យើងហើយ។ កណ្ឌគម្ពីរ យ៉ាកុប ៤:២ បានចែងថា «...មិនបានអ្វីសោះ ព្រោះអ្នករាល់គ្នាមិនទូលសូម»។

ប៉ុន្តែ ទោះបើយើងចំណាយពេលអធិស្ឋាន មានពេលខ្លះយើងក៏ចង់ឈប់អធិស្ឋានដែរ ពីព្រោះយើងតែងតែលើកនូវពាក្យពេចន៍ដដែលៗ ក៏ដូចជាសំណូមពរដដែលៗ។ រៀងរាល់ថ្ងៃដែលយើងក្រោកពីដំណេក យើងតែងតែប្រើពាក្យអធិស្ឋានដដែលៗ ហើយឆ្ងល់ថា ហេតុអ្វីបានជាជីវិតមិនមានការផ្លាស់ប្រែអ្វីបន្តិចសោះ?

នៅពេលដែលយើងដើរឆ្លងគន្លងនៃស្រមោលដែលមិនចេះផ្លាស់ប្រែ ហើយយើងភាគច្រើនបានទម្លាក់ទឹកមុខ ហើយរំពឹងចង់ឲ្យមានថ្ងៃដែលប្រសើរជាងនេះ។ ប៉ុន្តែ ព្រះគម្ពីរតែងតែលើកឡើងពីការអធិស្ឋានម្តងហើយម្តងទៀត ព្រោះតាមរយៈការអធិស្ឋាននឹងធ្វើឲ្យយើងបានទឹកមុខថ្មីផងឡើងវិញ។ ពិតប្រាកដណាស់ យើងប្រហែលស្គាល់សេចក្តីអធិស្ឋានរបស់ព្រះជាម្ចាស់ដែលព្រះយេស៊ូវបានបង្រៀននៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៦:៩-១៣ ប៉ុន្តែខទាំងប្រាំនេះមិនមែនជាជំនួយតែមួយគត់ដែលជួយការអធិស្ឋានរបស់យើងនោះទេ។ ព្រះជាម្ចាស់បានប្រទាននូវគំរូជាច្រើនដល់យើង ចេញពីការអធិស្ឋានដដែលៗ។ សូមមើលកណ្ឌគម្ពីរ ទំនុកដំកើង ៨៦ ជាគំរូ។ ខាងក្រោមនេះគឺជាការអធិស្ឋានប្រចាំថ្ងៃសាមញ្ញៗប្រាំពីរយ៉ាងដែលដកស្រង់ពីសេចក្តីអធិស្ឋានរបស់ស្តេច ដាវីឌ។

**១. សូមផ្ទៀងព្រះកាណ៌មកចំពោះសេចក្តីអធិស្ឋានរបស់ទូលបង្គំ**

«ឱព្រះយេហូវ៉ាអើយ សូមផ្ទៀងព្រះកាណ៌មក ចំពោះសេចក្តីអធិស្ឋានរបស់ទូលបង្គំ ហើយស្តាប់សំឡេងដែលទូលបង្គំអង្វរផង» (ទំនុកដំកើង ៨៦:៦)។
លោកអ្នកប្រហែលជាគិតថា ព្រះជាម្ចាស់បានព្រះសណ្តាប់ឮនូវរាល់សេចក្តីអធិស្ឋានរបស់ស្តេច ដាវីឌ ព្រោះទ្រង់បាននិពន្ធទំនុកជាច្រើននៅក្នុងកណ្ឌគម្ពីរ ទំនុកដំកើង ហើយបានទទួលជំនួយក្នុងការនិពន្ធនោះពីព្រះទៀត។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ទ្រង់នៅតែទូលសូម ឲ្យព្រះផ្ទៀងព្រះកាណ៌ស្តាប់ទ្រង់ម្តងហើយម្តងទៀត (ទំនុកដំកើង ៥:១; ១៧:៦; ២៧:៧; ២៨:២; ៣០:១០។ល។)។ តើលោកអ្នកធ្លាប់ទូលសូមព្រះជាម្ចាស់ឲ្យស្តាប់សេចក្តីអធិស្ឋានរបស់លោកអ្នកដែលឬទេ ឬលោកអ្នកគ្រាន់តែសន្មតថា ទ្រង់ព្រះសណ្តាប់លោកអ្នក?

ពេលខ្លះ យើងគិតថា ទោះបើយើងមិនសូមព្រះជាម្ចាស់ឲ្យជួយយើង ក៏ទ្រង់នឹងនៅតែជួយយើងដែរ។ យើងធ្លាប់ឮគេថា «ចូរសូមនូវអ្វីដែលឯងប្រាថ្នាចុះ នោះយើងនឹងឲ្យដល់ឯង» ហើយយើងក៏សន្មតថា ព្រះជាម្ចាស់មានព្រះជន្មគង់នៅ គឺដើម្បីនឹងបំពេញតម្រូវការរបស់យើង។ ការចង់បានបែបនោះគឺប្រៀបដូចជាយើងលួចអំណាចនៃក្តីសន្យារបស់ព្រះជាម្ចាស់ ហើយក៏កំពុងរារាំងយើងមិនឲ្យអធិស្ឋាន ហើយវានឹងធ្វើឲ្យយើងកាន់តែឆ្ងល់ថែមទៀត។

ព្រះដ៏មានពេញដោយព្រះចេស្តា ពេញដោយអធិបតេយ្យ និងជាព្រះអាទិករនៃផ្ទៃមេឃ និងផែនដី ទ្រង់ព្រះសណ្តាប់ឮនូវសេចក្តីអធិស្ឋានរបស់លោកអ្នក។ ប៉ុន្តែ សូមកុំយកដែលព្រះជាម្ចាស់សណ្តាប់ការអធិស្ឋានរបស់យើងជាgranted ឲ្យសោះ។ ចូរឲ្យស្គាល់ពីភាពបរិសុទ្ធរបស់ទ្រង់ និងបាបរបស់លោកអ្នកឲ្យបានច្បាស់ ដោយមិនត្រូវសន្មតថា ទ្រង់នឹងព្រះសណ្តាប់លោកអ្នកឡើយ ប៉ុន្តែព្រះជាម្ចាស់ព្រះសណ្តាប់ការអធិស្ឋានរបស់លោកអ្នក គឺដោយយល់ដល់ព្រះយេស៊ូវទៅវិញនោះទេ។ ចូរទូលសូមព្រះអង្គឲ្យព្រះសណ្តាប់ក្តីអធិស្ឋានរបស់លោកអ្នកមួយទៀតចុះ។

## ២. សូមការពារ និងរក្សាទូលបង្គំ

«សូមការពារព្រលឹងទូលបង្គំ ដ្បិតទូលបង្គំជាអ្នកជ្រះថ្លា ឱព្រះនៃទូលបង្គំអើយ សូមជួយសង្គ្រោះអ្នកបម្រើដែលទុកចិត្តដល់ទ្រង់ ឱព្រះអម្ចាស់អើយ សូមអាណិតមេត្តាដល់ទូលបង្គំផង ដ្បិតទូលបង្គំអំពាវនាវដល់ទ្រង់ជាដរាបរាល់ថ្ងៃ» (ទំនុកដំកើង ៨៦:២-៣)។

ពេលដែលស្តេច ដាវីឌ ប្រឈមមុខនឹងខ្មាំងសត្រូវ ទ្រង់បានសូមព្រះជាម្ចាស់ឲ្យការពារទ្រង់ ហើយរំដោះទ្រង់ចេញពីកណ្តាប់ដៃពួកគេ។ ខ្មាំងសត្រូវរបស់ទ្រង់តែងតែលោមព័ទ្ធទ្រង់ ហើយគំរាមកំហែងទ្រង់គ្រប់ពេលវេលា និងគ្រប់ទាំងចំណុច។ ប៉ុន្តែ ទ្រង់បានរកឃើញនូវក្តីសង្ឃឹម និងទំនុកចិត្តនៅក្នុងអធិបតេយ្យរបស់ព្រះ ហើយព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទ្រង់មិនដែលប្រែប្រួលឡើយ (ទំនុកដំកើង ១៨:២)។

យើងមានខ្មាំងសត្រូវដែលខ្លាំងពូកែ ហើយគួរឲ្យខ្លាចជាងខ្មាំងសត្រូវរបស់ស្តេច ដាវីឌ ឆ្ងាយណាស់ (១ពេត្រុស ៥:៨)។ វាបានរៀបចំឲ្យមានអ្នកសម្លាប់យើងគ្រប់ទីកន្លែង (អេភេសូរ ៦:១២) ហើយយើងក៏មិនអាចវាយឈ្នះវាដោយគ្មានអ្នកចម្បាំងដ៏ខ្លាំងម្នាក់មកវាយជំនួសយើងនោះ (អេភេសូរ ៦:១១)។

អ្នករាល់គ្នាបានទទួលសេចក្តីសង្គ្រោះ ហើយក៏កំពុងតែបានសង្គ្រោះរាល់ថ្ងៃ (១កូរិនថូស ១៥:២)។ ព្រះជាម្ចាស់ក៏កំពុងតែថែរក្សាលោកអ្នកដែរ (១ពេត្រុស ១:៥)។ ប៉ុន្តែ បើលោកអ្នកមិនអធិស្ឋាន នោះទ្រង់ក៏នឹងមិនធ្វើការដែរ (អេភេសូរ ៦:១៨)។ ពីមួយថ្ងៃ ទៅមួយថ្ងៃ យើងមានឱកាសថ្មីក្នុងការទូលសូមដោយមានទំនុកចិត្ត ឲ្យព្រះការពារ និងរក្សាយើង៖

«សូមឲ្យព្រះអង្គដែលអាចរក្សាអ្នករាល់គ្នាមិនឲ្យជំពប់ដួល និងបានដាក់អ្នករាល់គ្នាឲ្យនៅពីមុខសិរីរុងរឿងរបស់ព្រះអង្គដោយឥតបន្ទោសបាន និងដោយមានអំណរ គឺជាព្រះជាម្ចាស់តែមួយដែលជាព្រះអង្គសង្គ្រោះរបស់យើង តាមរយៈព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់របស់យើង បានប្រកបដោយសិរីរុងរឿង ភាពឧត្តុង្គឧត្តម ព្រះចេស្ដា និងសិទ្ធិអំណាច តាំងពីមុនអស់កល្បជានិច្ច ទាំងនៅពេលឥឡូវនេះដរាបអស់កល្បជានិច្ច។ អាម៉ែន។» (យូដាស ១:២៤-២៥ គគខ)។

## ៣. សូមបណ្ដាលឲ្យទូលបង្គំមានចិត្តរីករាយក្នុងទ្រង់

«សូមបណ្ដាលឲ្យព្រលឹងនៃអ្នកបម្រើទ្រង់ បានរីករាយឡើង ពីព្រោះ ឱព្រះអម្ចាស់អើយ ទូលបង្គំលើកព្រលឹងថ្វាយដល់ទ្រង់» (ទំនុកដំកើង ៨៦:៤)។

ព្រះជាម្ចាស់មិនមែនបង្កើតមនុស្សមក ដើម្បីសង្គ្រោះពួកគេតែប៉ុណ្ណោះនោះទេ ប៉ុន្តែ ដើម្បីឲ្យមានអំណរក្នុងព្រះសង្គ្រោះ។ អំពើបាបបានរារាំងផែនការដ៏ចម្បងរបស់ព្រះជាម្ចាស់ដែលមានចំពោះលោកអ្នក វាបានធ្វើឲ្យផែនការនោះរាំងស្ទះ។ ព្រះយេស៊ូវមិនគ្រាន់តែជាច្រកដែលនាំយើងចេញពីស្ថាននរកប៉ុណ្ណោះទេ ប៉ុន្តែក៏ច្រកដែលនាំយើងចូលទៅក្នុងព្រះវត្តមានរបស់ព្រះសង្គ្រោះដែលមានពេញដោយអំណរ និងកំណាប់ដ៏នៅស្ថិតស្ថេរ។ ព្រះជាម្ចាស់បានបង្កើតលោកអ្នកមក ដើម្បីឲ្យបង្ហាញភាពស័ក្តិសមរបស់ទ្រង់ដល់លោកីយ៍ ដោយធ្វើឲ្យយើងមានភាពអរសប្បាយក្នុងទ្រង់ ហើយព្រះអង្គមិនមែនគ្រាន់តែដាក់លោកអ្នកក្នុងស្ថានសួគ៌ប៉ុណ្ណោះទេ តែទ្រង់ថែមទាំងបានប្រទាននូវរូបអង្គទ្រង់ផ្ទាល់ដល់លោកអ្នកទៀតផង។

ព្រះជាម្ចាស់បានបង្គាប់ឲ្យយើងមានអំណរបែបនោះនៅក្នុងទ្រង់ (ទំនុកដំកើង ៣២:១១; លូកា ១០:២០; ភីលីព ៤:៤)។ ប៉ុន្តែ យើងដែលបានព្យាយាមធ្វើកិច្ចការនេះ ដឹងហើយថា យើងមិនអាចបំពាក់អំណរលើខ្លួនយើង ដូចយើងស្លៀកពាក់ខោអាវនោះឡើយ។ នៅក្នុងចិត្តរបស់យើង ដាច់ខាតត្រូវតែមានអធម្មជាតិកើតមានឡើង ហើយមានតែផ្លូវមួយប៉ុណ្ណោះដែលអធិធម្មជាតិនោះកើតមានឡើងគឺ មិនថាលោកអ្នកកំពុងឆ្លងកាត់រឿងរ៉ាវបែបណាក៏ដោយ ឬក៏លោកអ្នកឃ្លាតឆ្ងាយពីការមានអំណរប៉ុណ្ណាក៏ដោយ ក៏លោកអ្នកមិនគួរ គ្រាន់តែទទួលយកអំណរបន្តិចបន្តួចក្នុងនាមជាគ្រីស្ទបរិស័ទដែរ ហើយក៏កុំសន្មតថា លោកអ្នកនឹងអាចរកអំណរនោះបានតាម រយៈការមិនទូលសូមព្រះជាម្ចាស់នោះឡើយ។

## ៤. សូមបង្រៀនទូលបង្គំឲ្យស្គាល់ផ្លូវរបស់ទ្រង់

«ឱព្រះយេហូវ៉ាអើយ សូមបង្រៀនទូលបង្គំឲ្យស្គាល់ផ្លូវនៃទ្រង់ ទូលបង្គំនឹងដើរក្នុងសេចក្តីពិតរបស់ទ្រង់ សូមបំព្រួមចិត្តទូលបង្គំ មកឲ្យកោតខ្លាចដល់ព្រះនាមទ្រង់» (ទំនុកដំកើង ៨៦:១១)។

ព្រះជាម្ចាស់មិនគ្រាន់តែមានផែនការ ឲ្យស្គាល់សេចក្តីពិតអំពីទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ចង់ឲ្យលោកអ្នករស់នៅតាមសេចក្តីពិតទាំងនោះ។ លោកអ្នកអាចបង្ហាញតាមរយៈ៖

អ្វីដែលលោកអ្នកផ្តល់ជាអត្តិភាពចម្បង ទំនាក់ទំនង និងចិត្តរបស់លោកអ្នក។ ព្រះជាម្ចាស់បានសង្គ្រោះគ្រីស្ទបរិស័ទចេញពីកិច្ចការ (អាក្រក់) ដែលយើងធ្វើ (អេភេសូរ ២:៨) ហើយទ្រង់ក៏បានឲ្យយើងធ្វើកិច្ចការល្អផងដែរ ជាពិសេសកិច្ចការដែលទ្រង់បានរៀបចំសម្រាប់យើង តាំងពីមុនយើងកើតមកម្ល៉េះ (កាឡាទី ២:១៦; អេភេសូរ ២:១០)។

ប៉ុន្តែពេលខ្លះ យើងមានការពិបាកក្នុងការប្រព្រឹត្តនូវអ្វីដែលយើងដឹង ទៅនឹងការរស់នៅជាប្រចាំថ្ងៃ។ យើងមានការពិបាកក្នុងការរស់នៅ ដូចបែបដែលអង្គទ្រង់ស្រឡាញ់សព្វព្រះហឫទ័យឲ្យយើងរស់នៅណាស់។

ព្រះជាម្ចាស់មិនរំពឹកឲ្យយើងស្គាល់អំពីរបៀបនៃការរស់នៅដោយខ្លួនឯងនោះឡើយ តែទ្រង់សព្វព្រះហឫទ័យឲ្យយើងទូលសូមប្រាជ្ញា និងការណែនាំពីទ្រង់វិញ «ឱព្រះយេហូវ៉ាអើយ សូមបង្រៀនទូលបង្គំឲ្យស្គាល់ផ្លូវនៃទ្រង់» ហើយទ្រង់សព្វព្រះហឫទ័យនឹងធ្វើការនោះដោយរូបអង្គទ្រង់ផ្ទាល់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ចេញពីអ្វីៗដែលយើងធ្វើ។ លោកសាវ័ក ប៉ុល បានលើកឡើងក្នុងកណ្ឌគម្ពីរ ភីលីព ២:១២-១៣ ថា «ដូច្នេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ! ចូរសម្រេចឲ្យបាននូវសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយការកោតខ្លាច និងញាប់ញ័រចុះ គឺដូចដែលអ្នករាល់គ្នាបានស្តាប់បង្គាប់ជាដរាបមកហើយមិនមែនគ្រាន់តែនៅពេលដែលខ្ញុំនៅប៉ុណ្ណោះទេ ប៉ុន្តែឥឡូវនេះ នៅពេលខ្ញុំមិននៅ ចូរស្តាប់បង្គាប់ឲ្យកាន់តែខ្លាំងឡើងថែមទៀតចុះ ដ្បិតជាព្រះជាម្ចាស់ទេតើ ដែលធ្វើការនៅក្នុងអ្នករាល់គ្នា ទាំងឲ្យអ្នករាល់គ្នាមានឆន្ទៈ ហើយប្រព្រឹត្តតាម ដើម្បីឲ្យព្រះអង្គសព្វព្រះហឫទ័យ។» (គគខ)។

៥. សូមប្រទានកម្លាំងរបស់ទ្រង់ដល់ទូលបង្គំ

«ឱសូមវិលមកឯទូលបង្គំវិញ ហើយអាណិតមេត្តាដល់ទូលបង្គំផង សូមប្រទានកម្លាំងរបស់ទ្រង់ មកទូលបង្គំជាអ្នកបម្រើទ្រង់ ហើយជួយសង្គ្រោះកូនរបស់ស្ត្រីជាអ្នកបម្រើទ្រង់ដែរ» (ទំនុកដំកើង ៨៦:១៦)។

មានអ្នកខ្លះនៅក្នុងចំណោមយើង មិនចាំបាច់មានអ្នកដទៃមកប្រាប់យើងឲ្យខំធ្វើការនោះទេ ក្រោយពេលយើងងើបពីគេង យើងមានចិត្តចង់ធ្វើការរួចទៅហើយ ប៉ុន្តែយើងតែងតែភ្លេចសូមអ្នកដទៃឲ្យជួយយើង ឬក៏បម្រើដោយពឹងលើកម្លាំងអ្នកដទៃជាជាងកម្លាំងខ្លួនឯង។ ការរស់នៅបែបនេះ អាចមានប្រសិទ្ធភាពសម្រាប់មួយរយៈ ប៉ុន្តែមិនយូរមិនឆាប់យើងនឹងអស់កម្លាំង។ នៅក្នុងកណ្ឌគម្ពីរ ទំនុកដំកើង ១២៧:២ បានចែងថា «ការដែលឯងក្រោកឡើងមុនកំណត់ ហើយក្រចូលដេកពេលយប់ ព្រមទាំងបរិភោគដោយធ្វើការនឿយហត់ផង នោះជាការឥតប្រយោជន៍ទៀត ដ្បិតទ្រង់ប្រោសប្រទានឲ្យពួកស្ងួនភ្ងារបស់ទ្រង់ បានដេកលក់សប្បាយ»។

ចូរខំធ្វើការ ប៉ុន្តែចូរកុំពឹងលើកម្លាំងខ្លួនឡើយ តែពឹងលើកម្លាំងដែលព្រះជាម្ចាស់ប្រទានវិញ ហើយអនុញ្ញាតឲ្យទ្រង់ទទួលយកសិរីល្អដែលទ្រង់សក្តិសមនឹងទទួលវិញ (១ពេត្រុស ៤:១១)។ ព្រះជាម្ចាស់នឹងមិនផ្តល់កម្លាំងទ្រង់ដល់អស់អ្នកអាត្មានិយមដែលនឹងយកកម្លាំងនោះ ទៅបំពេញចិត្តក្នុងការទិញសម្ភារ:និយមឡើយ ប៉ុន្តែទ្រង់នឹងប្រទានកម្លាំងបែបអធម្មជាតិ ដើម្បីបម្រើ។ ព្រះអង្គនឹងប្រទានភាពក្លាហានដល់លោកអ្នក ហើយនឹងជួយលោកអ្នកឲ្យចេះលះបង់ជីវិតខ្លួនឯង ដើម្បីប្រយោជន៍អ្នកដទៃក្នុងព្រះនាមទ្រង់។

## ៦. សូមបំព្រួមចិត្តទូលបង្គំមកឲ្យកោតខ្លាចទ្រង់

«...សូមបំព្រួមចិត្តទូលបង្គំមកឲ្យកោតខ្លាចដល់ព្រះនាមទ្រង់» (ទំនុកដំកើង ៨៦:១១)។

ចិត្តរបស់យើងដែលមានពេញទៅដោយអំពើបាប តែងតែចង់មានការបែកបាក់ជាជាងការរួបរួម។ ទោះបើយើងកាន់តែចង់មានចិត្តឲ្យដូចព្រះជាម្ចាស់ ក៏យើងនៅតែមានចិត្តប្រាថ្នាចង់បះបោរទាស់នឹងទ្រង់ដដែល ខណៈពេលដែលយើងនៅមានជីវិត។ ការរស់នៅបែបជាគ្រីស្ទបរិស័ទមានន័យថា យើងត្រូវតែបន្តព្យាយាមសម្លាប់អំពើបាប (រ៉ូម ៨:១៣) ដែលការនេះមានន័យថា សព្វថ្ងៃនេះនៅមានអំពើបាបដែលយើងត្រូវសម្លាប់ (១យ៉ូហាន ១:៨)។

ប្រសិនបើយើងមិនយកចិត្តទុកដាក់ក្នុងជីវិតរស់នៅរបស់យើង នោះជីវិតយើងនឹងមិនឆ្ពោះទៅរកព្រះគ្រីស្ទឡើយ យើងនឹងរត់ចេញពីព្រះជាម្ចាស់ទាំងស្រុងតែម្តង។ អំពើបាបដែលមាននៅជាប់ក្នុងខ្លួនយើង តែងតែបំបែកចំណោមអារម្មណ៍ និងក្តីស្រឡាញ់យើងចេញពីព្រះជាម្ចាស់។ ដូច្នេះ យើងគួរតែចំណាយពេលអធិស្ឋានឲ្យបានញឹកញាប់ ក្នុងការទូលសូមទ្រង់ឲ្យដកការបែកអារម្មណ៍បែបនោះចេញពីចិត្តយើង ហើយជួយយើងឲ្យ

មានចិត្តរួមនឹងទ្រង់។

## ៧. សូមប្រើទូលបង្គំក្នុងការសម្តែងឲ្យអ្នកដទៃឃើញទ្រង់

«សូមសម្តែងទីសំគាល់១ពីសេចក្តីល្អ ដែលនឹងប្រោសដល់ទូលបង្គំ ដើម្បីឲ្យពួកអ្នកដែលស្អប់ទូលបង្គំបានឃើញ ហើយមានសេចក្តីខ្មាសវិញ ដោយព្រោះទ្រង់ ឱព្រះយេហូវ៉ាអើយ ទ្រង់បានជួយ ហើយកំសាន្តចិត្តនៃទូលបង្គំហើយ» (ទំនុកដំកើង ៨៦:១៧)។

ការដែលព្រះជាម្ចាស់បង្ហាញថា ទ្រង់គាប់ព្រះហឫទ័យចំពោះយើងតាមរយៈការដែលទ្រង់ឆ្លើយតបសំណូមពរអធិស្ឋានយើង គឺមិនមែនគ្រាន់តែ សម្រាប់ឲ្យយើងមានក្តីសង្ឃឹម ក្តីអំណរ និងកម្លាំងប៉ុណ្ណោះទេ តែទ្រង់ក៏ចង់បង្ហាញការនោះដល់លោកីយ៍ទាំងមូលផងដែរ។ ទោះបើភាគច្រើនយើងផ្តោតសំណូមពរអធិស្ឋានរបស់យើងលើកាលៈទេសៈរបស់ខ្លួនក៏ដោយ ក៏យើងគួរព្យាយាមចំណាយពេលខ្លះ ដើម្បីទូលសូមព្រះឲ្យលោកីយ៍នេះឃើញពីអ្វីដែលយើងឃើញ និងអំណរដែលយើងមានក្នុងទ្រង់ផងដែរ។

ព្រះយេស៊ូវបានមានបន្ទូលថា «ចូរឲ្យពន្លឺអ្នករាល់គ្នាភ្លឺនៅចំពោះមុខមនុស្សយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អរបស់អ្នករាល់គ្នា រួចសរសើរតម្កើងព្រះវរបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌» (ម៉ាថាយ ៥:១៦ គគខ)។ ហើយសាវ័ក ពេត្រុស ក៏បានលើកឡើងស្រដៀងនឹងព្រះយេស៊ូវដែរ «ទាំងមានកិរិយាល្អនៅក្នុងចំណោមសាសន៍ដទៃចុះ ដើម្បីឲ្យគេសរសើរតម្កើងព្រះជាម្ចាស់នៅថ្ងៃប្រោសលោះ ដោយបានឃើញអំពើល្អរបស់អ្នករាល់គ្នា ទោះបីគេធ្លាប់និយាយមួលបង្កាច់អ្នករាល់គ្នាទុកដូចជាអ្នកប្រព្រឹត្តអាក្រក់ក៏ដោយ» (១ពេត្រុស ២:១២ គគខ)។

យើងគួរតែចង់ឲ្យលោកីយ៍ដែលកំពុងមើលយើង ឃើញពីជំនឿរបស់យើង តាមរយៈជីវិតរស់នៅរបស់យើង។ យើងឲ្យអ្នកមិនជឿព្រះគ្រីស្ទឃើញ ហើយជឿថា ព្រះយើងគឺជាព្រះដ៏ពិតតែមួយប៉ុណ្ណោះ។ ហើយលើសពីនោះ យើងក៏ចង់ឲ្យពួកគេស្គាល់ទ្រង់ផ្ទាល់ ក៏ដូចជាទទួលបានការសង្គ្រោះតែម្តង។

ចេញពីក្តីអធិស្ឋានរបស់យើង យើងគួរសូមព្រះជាម្ចាស់ឲ្យយកនូវអ្វីដែលទ្រង់កំពុងធ្វើសម្រាប់យើង និងនៅក្នុងយើងទៅប៉ះពាល់ចិត្តគំនិតអ្នកដទៃ ឲ្យបានខ្លាំងតាមរយៈយើង។

**ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។**

**និពន្ធដោយ៖ លោកគ្រូ Marshall Segal**

**បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ជួប ប៊ុនហាក់**

**ដកស្រង់ខ្លះៗចេញពី www.desiringgod.org ដោយមានការអនុញ្ញាត។**